**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៤៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងទួលបុស្សភ្ញៀវ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងទួលបុស្សភ្ញៀវដែលមានផ្ទៃដីទំហំ១២៥២,៣៧(មួយពាន់ពីររយ

ហាសិបពីរហិចតានិងសាមសិបប្រាំពីរអា) ស្ថិតក្នុងភូមិសាស្ត្រ ឃុំព្រៃកមាស ឃុំស្រែសំបូរ និងឃុំសេកុង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា(UTM WGS 1984 Zone 48 N) ដូចខាងក្រោម៖

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 642890.51 | 1559127.68 | 17 | 645874.69 | 1557231.84 | 33 | 644254.19 | 1554025.66 |
| 2 | 643190.45 | 1559006.21 | 18 | 646422.21 | 1556866.4 | 34 | 644524.84 | 1554029.03 |
| 3 | 643087.73 | 1558857.07 | 19 | 646306.96 | 1556622.67 | 35 | 644655.92 | 1554324.57 |
| 4 | 643214.37 | 1558759.13 | 20 | 646000.46 | 1556456.33 | 36 | 644305.64 | 1554750.84 |
| 5 | 643492.98 | 1558830.05 | 21 | 645783.61 | 1556249.32 | 37 | 643874.67 | 1555046.02 |
| 6 | 644210.28 | 1558410.02 | 22 | 646209.27 | 1555841.76 | 38 | 643780.14 | 1555538.76 |
| 7 | 644145.07 | 1557715.62 | 23 | 646272.74 | 1555628.11 | 39 | 643478.66 | 1555736.66 |
| 8 | 643873.9 | 1557078.94 | 24 | 646728.15 | 1555495.39 | 40 | 643281.2 | 1556431.93 |
| 9 | 644089.4 | 1556898.47 | 25 | 646274.77 | 1554694.24 | 41 | 642710.17 | 1556620.07 |
| 10 | 644142.63 | 1556977.29 | 26 | 646067.7 | 1554272.44 | 42 | 642255.66 | 1556984.96 |
| 11 | 644671.57 | 1556523.98 | 27 | 645858.74 | 1553915.2 | 43 | 641578.56 | 1557356.12 |
| 12 | 644937.14 | 1556684.42 | 28 | 646004.13 | 1553804.02 | 44 | 641477.53 | 1557711.39 |
| 13 | 644886.31 | 1556820.88 | 29 | 645561.25 | 1553667.81 | 45 | 641712.77 | 1558250.4 |
| 14 | 645063.36 | 1556923.9 | 30 | 645474 | 1553392.36 | 46 | 642296.76 | 1558410.14 |
| 15 | 645450.47 | 1557232.06 | 31 | 645238.62 | 1553205.16 | 47 | 642366.55 | 1558539.6 |
| 16 | 645548.79 | 1557021.82 | 32 | 644493.9 | 1553402.67 | 48 | 642430.8 | 1558818.21 |

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាការថែរក្សានិងការពារសោភ័ណភាពធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី សារព័នមជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិ និងវប្បធម៌
- ថែរក្សាការពារលំនឹងបរិស្ថាននិងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្ដល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់
- ថែរក្សាការពារ វប្បធម៌ ប្រពៃណី ការអភិវឌ្ឍ និងសារៈសំខាន់ផ្នែកវប្បធម៌របស់សហគមន៍មូលដ្ឋាន
- បង្កើនតួនាទីប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ សម្រាប់ជាផលប្រយោជន៍ដល់សង្គមជាតិគ្រប់ជំនាន់។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំនិងគ្រប់គ្រងតំបន់ប្រើប្រាស់ច្រើនយ៉ាងទួលបុស្សភ្លៀវ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តស្ទឹងត្រែង និងកងកម្លាំងប្រដាប់អាវុធមានសមត្ថកិច្ច ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ .-**

ព្រំប្រទល់និងផ្ទៃក្រឡាតំបន់ប្រើប្រាស់ច្រើនយ៉ាងទូលំទូលាយ អាចត្រូវធ្វើបច្ចុប្បន្នភាពនិងកែសម្រួលតាមរយៈការសិក្សាស្រាវជ្រាវនិងប្រមូលទិន្នន័យ ដោយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ ដើម្បីជានាតម្លៃ និងផលប្រយោជន៍ធនធានជីវៈចម្រុះ សេដ្ឋកិច្ច សង្គម និងវប្បធម៌ អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១ នៃអនុក្រឹត្យលេខ: ៧៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែ មេសា ឆ្នាំ២០២៣

ផែនទីតំបន់ប្រើប្រាស់ច្រើនយ៉ាងទួលបុស្សរៀង ស្ថិតក្នុងភូមិសាស្ត្រស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង






តំបន់ប្រើប្រាស់ច្រើនយ៉ាងទួលបុស្សរៀង

មានទំហំផ្ទៃដី ១ ២៥២,៣៧ ហិចតា

មាត្រដ្ឋាន 1:40,000

0 0.5 1 Km

**សញ្ញាសម្គាល់**

- ចំណុចនិយាមកា
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

*Map Coordinate System:*
*Units: Meter*
*System Projection: UTM, Zone 48N*
*Datum: WGS 1984*